ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ផលិតកម្ម អាហរណ-នីហរណកម្ម និងពាណិជ្ជកម្ម ឱសថបូរាណ សំរាប់វិស័យសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រក/០១៩៦/០៣ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០១៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ សីហា ១៩៩៧ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល
- បានការអនុម័តរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី ១២ ខែ មិនា ឆ្នាំ ១៩៩៨

សំ ៦ ៖ ច

※※※

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

មាត្រា ១. អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងផលិតកម្ម អាហរ័ណ-និហរ័ណកម្ម និងពាណិជ្ជកម្មឱសថបូរាណ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២. ឱសថបូរាណគឺជាសារជាតិសំរាប់ប្រើប្រាស់ក្នុងការបង្ការ ឬព្យាបាលជម្ងឺ មនុស្ស សត្វ មាន ៖

-រុក្ខជាតិ ឬសត្វ ឬសិលាជាតិដែលមិនទាន់កែច្នៃ ឬបានកែច្នៃតាមវិធីសាស្ត្រសាមញ្ញ

-ផលិតផលដែលផ្សំ ឬផលិតឡើងដោយសារជាតិមួយមុខ ឬច្រើនមុខ ដែលមានរចនាសម្ព័ន្ធគីមីមិនទាន់ច្បាស់លាស់ និងមានប្រភពពីរុក្ខជាតិ សត្វ ឬសិលាជាតិ ។

មាត្រា ៣. ផលិតកម្ម អាហរ័ណ-និហរ័ណកម្ម និងពាណិជ្ជកម្មឱសថបូរាណ អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

## ជំពូកទី ២
## សិទ្ធិធ្វើអាជីវកម្មឱសថបុរាណ

មាត្រា ៤. ឱសថការីដែលអាចមានសិទ្ធិធ្វើផលិតកម្ម អាហរ័ណ-និហរ័ណកម្ម ឱសថបូរាណ បាន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានសញ្ញាប័ត្រជាឱសថការី ទទួលស្គាល់ដោយក្រសួងសុខាភិបាល

-មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ

-មានសុខភាពគ្រប់គ្រាន់ អាចបំពេញការងារបាន ។

មាត្រា ៥. គ្រូថ្នាំបូរាណដែលអាចមានសិទ្ធិធ្វើពាណិជ្ជកម្មឱសថបូរាណ បាន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានការយល់ដឹងក្នុងការផ្សំឱសថបូរាណពីរុក្ខជាតិ សត្វ ឬសិលាជាតិ និងការពិនិត្យព្យាបាលជម្ងឺសាមញ្ញតាមវេជ្ជសាស្ត្របូរាណ ដែលមានវិញ្ញាបនប័ត្រគ្រូថ្នាំបូរាណ ទទួលស្គាល់ដោយក្រសួងសុខាភិបាល

-មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ
-មានសុខភាពគ្រប់គ្រាន់ អាចបំពេញការងារបាន ។

មាត្រា ៦. ក្រសួងសុខាភិបាល អាចអនុញ្ញាតឱ្យឱសថការី និងគ្រូថ្នាំបូរាណបរទេសប្រកបវិជ្ជាជីវៈឱសថបូរាណក្នុងព្រះរាជាណាចក្រកម្ពុជាបាន ក្នុងករណីយល់ឃើញថា មានតម្រូវការចាំបាច់ក្នុងសង្គមជាតិ ។

មាត្រា ៧. ឱសថបូរាណដែលអាចផលិត អាហរណ៍-នីហរណ៍បាន ត្រូវមានទិដ្ឋាការ ឬបញ្ជិកាយល់ព្រមពីក្រសួងសុខាភិបាល ។

មាត្រា ៨. ក្រសួងសុខាភិបាលកំណត់ដោយប្រកាសនូវ ៖
-បែបបទ និងល័ក្ខខ័ណ្ឌ ក្នុងការសុំបើក ឬប្ដូរទីតាំង-ឬផ្ទេរម្ចាស់ទីធំនៃគ្រឹះស្ថានផលិត គ្រឹះស្ថានអាហរណ៍-នីហរណ៍ និងអគារលក់ឱសថបូរាណ ។
-បែបបទ និងល័ក្ខខ័ណ្ឌក្នុងការសុំទិដ្ឋាការ ឬបញ្ជិកាឱសថបូរាណ
-បែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសគ្រប់គ្រង និងថែរក្សាឱសថបូរាណ
-បែបបទ និងល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយឱសថបូរាណ
-បែបបទ ផលិតកម្ម អាហរណ៍-នីហរណកម្ម និងពាណិជ្ជកម្មឱសថបូរាណ ។

មាត្រា ៩. ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាលចំពោះ ៖
-ការបើក ការប្ដូរទីតាំង និងការប្ដូរអ្នកទទួលខុសត្រូវនៃគ្រឹះស្ថានផលិត គ្រឹះស្ថានអាហរណ៍-នីហរណ៍ និងអគារលក់ឱសថបូរាណ
-ការផលិត អាហរណ៍-នីហរណ៍ ស្តុកឱសថបូរាណ និងវត្ថុធាតុដើមសំរាប់ផលិតឱសថបូរាណ
-ការផ្សព្វផ្សាយឱសថបូរាណ ។

## ជំពូកទី ៣
## ផលិតកម្មឱសថបូរាណ

មាត្រា ១០. ផលិតកម្មឱសថបូរាណជាទ្រង់ទ្រាយឧស្សាហកម្ម ត្រូវប្រព្រឹត្តទៅនៅក្នុងគ្រឹះស្ថានផលិតឱសថ ដែលមានការរៀបចំសមស្រប តាមល័ក្ខខ័ណ្ឌបច្ចេកទេសកំណត់ដោយប្រកាសក្រសួងសុខាភិបាល ។

មាត្រា ១១. ផលិតកម្មឱសថបូរាណ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការទទួលខុសត្រូវរបស់ឱសថការីមួយរូប ឬច្រើនរូបទៅតាមទំហំផលិតកម្ម

## ជំពូកទី ៤
## អាហរ័ណ-នីហរ័ណកម្មឱសថបូរាណ

មាត្រា ១២. អាហរ័ណ-នីហរ័ណកម្មឱសថបូរាណ ត្រូវប្រព្រឹត្តឡើងតាមរយៈគ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ ដែលមានការរៀបចំសមស្រប តាមលក្ខខ័ណ្ឌកំណត់របស់ក្រសួងសុខាភិបាល ។

មាត្រា ១៣. ឱសថបូរាណដែលសុំនាំចូល ត្រូវជ្រើសរើសក្នុងបញ្ជីឱសថបូរាណ ដែលបានចុះបញ្ជិការួចហើយនៅក្រសួងសុខាភិបាល ។
ឱសថបូរាណដែលបាននាំចូលហើយ ត្រូវមានទម្រង់បង្ហាញ និង មានគុណភាពល្អត្រឹមត្រូវតាមឱសថគំរូដែលបានតំកល់ ។

## ជំពូកទី ៥
## ពាណិជ្ជកម្មឱសថបូរាណ

មាត្រា ១៤. ការតាំងលក់ ការលក់និងការស្តុកឱសថបូរាណ ត្រូវប្រព្រឹត្តទៅនៅក្នុងអគារលក់ឱសថបូរាណ ដែលមានការរៀបចំសមស្រប តាមល័ក្ខខ័ណ្ឌកំណត់របស់ក្រសួងសុខាភិបាល។

មាត្រា ១៥. អគារលក់ឱសថបូរាណត្រូវមានវត្តមានរបស់គ្រូបូរាណ ដើម្បីគ្រប់គ្រងសកម្មភាពក្នុងអគាររបស់ខ្លួន ។
ករណីអវត្តមាន គ្រូថ្នាំបូរាណទទួលខុសត្រូវ ត្រូវមានគ្រូថ្នាំបូរាណមួយរូបទៀតជំនួស ដោយមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

មាត្រា ១៦. ត្រូវហាមឃាត់ ៖
១-ការលក់ឱសថបូរាណក្លែងក្លាយ គ្មានគុណភាព
២-ការលក់ឱសថបូរាណ ដែលផ្សំលាយជាមួយឱសថសម័យ
៣-ការលក់ឱថបូរាណគ្រោះថ្នាក់ ដែលមានក្នុងបញ្ជីហាមឃាត់របស់ក្រសួងសុខាភិបាល
៤-ការប្រកបអាជីវកម្មផ្សេងទៀតក្នុងអគារលក់ឱសថបូរាណ ។

# ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.** សហរដ្ឋមន្ត្រីទទួលបន្ទុកគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួង ស្ថាប័ន ពាក់ព័ន្ធមានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

អ៊ឹង ហួត ហ៊ុន សែន

បានជំរាបជូន :

- ឯកឧត្តម នាយករដ្ឋមន្ត្រីទី ១
- សម្តេច នាយករដ្ឋមន្ត្រីទី ២

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

[illegible] ឈា. ថាំង

បម្លងជូន

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តម នាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ១៨
- ឯកសារ កាលប្បវត្តិ